**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**គម្រោង ធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និង សំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា**
**IDA Grant No. 7292-KH**

# ដំណឹងជ្រើសរើសបុគ្គលិក

១. រាជរដ្ឋាភិបាលកម្ពុជាបានទទួលឥណទាន សម្បទានពីធនាគារពិភពលោក( IDA Grant No. 7292) សម្រាប់អនុវត្តគម្រោង ធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា សម្រាប់រយៈពេល ៦ឆ្នាំ (២០២៣ ដល់ ២០២៩) មានថវិកាសរុប ៦៧,៣ លានដុល្លាអាមេរិកដែលចែកជាបីសមាសភាគ។ ក្រសួងមហាផ្ទៃជាភ្នាក់ងារប្រតិបត្តិគម្រោង សមាសភាគទី២ ដែលមាន ថវិកា៨,៤២លានដុល្លាអាមេរិក។ គម្រោង ធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជានៃ ក្រសួងមហាផ្ទៃ ត្រូវការជ្រើសរើស ១. អ្នកបើកបរ ចំនួន ០២នាក់ និង២. អ្នកអនាម័យ ចំនួន ០១នាក់។

**ក. មុខដំណែង** : អ្នកបើកបរ (០២នាក់)

**ទីកន្លែង** : ក្រសួងមហាផ្ទៃ

**រយៈពេល** : ១២ខែ (អាចបន្តផ្អែកតាមការវាយតម្លៃលើលទ្ធផលនៃការអនុវត្តការងារប្រចាំឆ្នាំ)

**ក.១ បេក្ខជនត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម ៖**

- ជាជនជាតិខ្មែរ
- មានកម្រិតសិក្សាចាប់ពីថ្នាក់ទី១២
- មានអាយុចាប់ពី១៨ឆ្នាំ ដល់៥៥ឆ្នាំ
- មានបទពិសោធន៍បើកបររថយន្ត(លេខដៃ និងលេខអូតូ)យ៉ាងតិច០៥ឆ្នាំ មានបណ្ណបើកបរដែលមានសុពលភាព និងស្របច្បាប់
- យល់ដឹងពីច្បាប់ចរាចរណ៍ និងចេះថែទាំជួសជុលរថយន្តខ្លះៗ
- មានកាយសម្បទា និងសុខភាពល្អ និងអាចចុះធ្វើការតាមខេត្តនានាបាន
- មានភាពស្មោះត្រង់ សុភាពរាបសារ គោរពវិន័យ វិជ្ជាជីវៈ និងមិនធ្លាប់មានទោស ឬជាប់ក្នុងបទឧក្រិដ្ឋ
- ឧស្សាហ៍ព្យាយាម និងអំណត់ក្នុងការងារ
- អាចអាន និងសរសេរភាសាអង់គ្លេសបានកាន់តែប្រសើរ។

**ក.១ ភារកិច្ច និងការទទួលខុសត្រូវ ៖**

- ត្រូវធានាឱ្យបាននូវសុវត្ថិភាពក្នុងការបើកបរ និងថែទាំរថយន្តឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- ត្រូវត្រួតពិនិត្យលក្ខណៈបច្ចេកទេសរថយន្ត និងសម្អាតរថយន្តរៀងរាល់មុនពេលចេញដំណើរចុះបំពេញបេសកកម្ម និងត្រឡប់មកវិញ
- ត្រូវកត់ត្រាសកម្មភាពបើកបរ និងការងារប្រចាំថ្ងៃចូលក្នុងសៀវភៅតាមដានការប្រើប្រាស់រថយន្ត
- ត្រូវរាយការណ៍ដោយស្មោះត្រង់ និងឆាប់បំផុតនូវរាល់បញ្ហា ឬបាតុភាពផ្សេងៗក្នុងពេលបើកបរ
- ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាននូវរាល់កំហុសឆ្គង និងការបង្កគ្រោះថ្នាក់ចរាចរណ៍ដែលកើតឡើងពីការធ្វេសប្រហែស ឬការរំលោភបំពានច្បាប់ចរាចរណ៍
- ត្រូវបំពេញភារកិច្ចចាំបាច់ផ្សេងៗទៀត។

**ខ. មុខដំណែង** : អ្នកអនាម័យ (១នាក់)

**ទីកន្លែង** : ការិយាល័យប្រតិបត្តិគម្រោងក្រសួងមហាផ្ទៃ

**រយៈពេល** : ១២ខែ (អាចបន្តផ្អែកតាមការវាយតម្លៃលើលទ្ធផលនៃការអនុវត្តការងារប្រចាំឆ្នាំ)

**ខ.១ គុណវុឌ្ឍិ និងបទពិសោធន៍ដែលពាក់ព័ន្ធ**

- ជនជាតិខ្មែរ
- មានអាយុចាប់ពី១៨ឆ្នាំ ដល់៥៥ឆ្នាំ
- មានកាយសម្បទា និងសុខភាពល្អ និងអាចចុះធ្វើការតាមខេត្តនានាបាន

- មានភាពស្មោះត្រង់ សុភាពរាបសារ គោរពវិន័យ វិជ្ជាជីវៈ និងមិនធ្លាប់មានទោស ឬជាប់ក្នុងបទឧក្រិដ្ឋ
- ឧស្សាហ៍ព្យាយាម និងអំណត់ក្នុងការងារ

**ខ.២ ភារកិច្ចទទួលខុសត្រូវ**

- រៀបចំទុកដាក់ បោស ជូត សម្អាត តុ ទូ និងសម្ភារក្នុងបន្ទប់ធ្វើការ និងបន្ទប់ប្រជុំជាប្រចាំ
- រៀបចំអាហារសម្រន់សម្រាប់កិច្ចប្រជុំនានា
- ជួយរៀបចំបន្ទប់ប្រជុំ និងសម្អាតបន្ទប់ប្រជុំបន្ទាប់ពីប្រជុំរួចរាល់
- រាយការណ៍ពីតម្រូវការទិញសម្ភារៈ និងឧបករណ៍អនាម័យដើម្បីបំរើការងារអនាម័យប្រចាំថ្ងៃ
- វេចខ្ចប់ និងទុកដាក់សំរាមឱ្យបានត្រឹមត្រូវ
- ត្រូវបំពេញភារកិច្ចចាំបាច់ផ្សេងៗទៀត។

២ .បេក្ខជនដែលមានលក្ខណៈសម្បត្តិសមស្របនឹងត្រូវបានសម្រាំង និងទទួលបានការសម្ភាសន៍ស្ទង់សមត្ថភាព មុននឹងត្រូវបានសម្រេចឱ្យចូលបម្រើការងារជាបុគ្គលិកជាប់កិច្ចសន្យា។

៣ .បេក្ខជនដែលមានចំណាប់អារម្មណ៍សម្រាប់មុខតំណែងទាំងពីរខាងលើនេះ អាចសាកសួរព័ត៌មាន និងដាក់ពាក្យ មកអាសយដ្ឋានដូចខាងក្រោម៖ ក្រសួងមហាផ្ទៃ បន្ទប់លេខ ៣៥៦ ជាន់ទី ៣ មហាវិថី ព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមនរាជធានីភ្នំពេញ ឬតាមសារអេឡិចត្រូនិច dst.samreth@gmail.com និងទូរសព្ទលេខ ០១២ ៣៧៦ ១៧៥ ឱ្យបានមុនថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២៤ វេលាម៉ោង០៥:៣០នាទីល្ងាច ជាកំណត់។

៤ .បេក្ខជនត្រូវភ្ជាប់មកជាមួយនូវ៖ ជីវប្រវត្តិសង្ខេបដែលមានបិតរូបថត ច្បាប់ចម្លងប័ណ្ណបើកបរ ឬឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងបទពិសោធន៍ការងាររបស់ខ្លួន។